ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# បឹងក្រពិត
## រយៈពេល ៥ ឆ្នាំ (២០១៧-២០២២)

ឈ្មោះសហគមន៍នេសាទ ៖ បឹងក្រពិត

ភូមិ ៖ កន្លែងចក ស្វាយពក ថ្មី ថ្មសំលៀង បឹងជើង មៀន សោយ មេលោង កំពូលសេរី បន្ទាយមៀន និងបឹងកណ្តាល

ឃុំ ៖ មៀន

ភូមិ ៖ បឹងកាង ស្រែមៀន ទួលឃ្លាំង ទួលមានជ័យ បាស្រី ព្រះធាតុកណ្តាល និងព្រះធាតុថ្មដា

ឃុំ ៖ ព្រះធាតុ

ស្រុក ៖ អូររាំងឪ

ខេត្ត ៖ ត្បូងឃ្មុំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បឹងក្រពិត
# រយៈពេល ៥ ឆ្នាំ (២០១៧-២០២២)

រៀបចំដោយរដ្ឋបាលជលផល ឧបត្ថម្ភដោយ FAO

ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧

ឈ្មោះសហគមន៍នេសាទ ៖ **បឹងក្រពិត**

ភូមិ ៖ កន្លែងចក ស្វាយពក ថ្មី ថ្មសំលៀង បឹងដើង មៀន សោយ មេលោង កំពូលសេរី បន្ទាយមៀន និងបឹងកណ្ដាល

ឃុំ ៖ មៀន

ភូមិ ៖ បឹងកាង ស្រែមៀន ទួលឃ្លាំង ទួលមានជ័យ បាស្រី ព្រះធាតុកណ្ដាល និងព្រះធាតុថ្មដា

ឃុំ ៖ ព្រះធាតុ

ស្រុក ៖ អូររាំងឪ

ខេត្ត ៖ ត្បូងឃ្មុំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បឹងក្រពិត រយៈពេល ៥ ឆ្នាំ (២០១៧-២០២២)

រៀបចំដោយរដ្ឋបាលជលផល ឧបត្ថម្ភដោយ FAO
ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧

| | | |
|---|---|---|
| **ឈ្មោះសហគមន៍នេសាទ** | ៖ | **បឹងក្រពិត** |
| ភូមិ | ៖ | កន្លែងចក ស្វាយពក ថ្មី ថ្មសំលៀង បឹងជើង មៀន សោយ មេលោង កំពូលសេរី បន្ទាយមៀន និងបឹងកណ្តាល |
| ឃុំ | ៖ | មៀន |
| ភូមិ | ៖ | បឹងកាង ស្រែមៀន ទួលឃ្លាំង ទួលមានជ័យ បាស្រី ព្រះធាតុកណ្តាល និងព្រះធាតុថ្មដា |
| ឃុំ | ៖ | ព្រះធាតុ |
| ស្រុក | ៖ | អូររាំងឪ |
| ខេត្ត | ៖ | ត្បូងឃ្មុំ |

## មាតិកា

## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១- ស្ថានភាពទូទៅ**

**២- អំពីប្រជាសាស្ត្រ**

ក- ប្រជាពលរដ្ឋ

ខ- មុខរបរ

**៣- កន្លែងនេសាទសហគមន៍និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

ក- ទីតាំង

ខ- ដែននេសាទ

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស

ឃ- ធនធានជលផល

**៤- ការធ្វើនេសាទ**

ក- អ្នកនេសាទ

ខ- ឧបករណ៍នេសាទ

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**

ក- ទស្សនៈវិស័យ

ខ- គោលបំណង

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ

គ២- ផែនការកែលម្អដែននេសាទ

គ៣- ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស

គ៤- ផែនការគ្រប់គ្រងព្រៃលិចទឹក

គ៥- ផែនការទប់ស្កាត់បទល្មើសជលផល

គ៦- ផែនការប្រជុំប្រចាំខែនិងសម្ភារៈអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ

គ៧- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

គ៨- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ

គ៩- ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងសហគមន៍នេសាទ

គ១០- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ

គ១១- ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ

គ១២- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ

គ១៣- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ឃ. ផែនការយុទ្ធសាស្ត្រ

- តារាងកម្មវិធីការងារ

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទបឹងក្រពិត បានធ្វើមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

សហគមន៍នេសាទបឹងក្រពិត មានទីតាំងស្ថិតនៅភូមិកន្លែងចក ស្វាយពក ថ្មី ថ្នសំលៀង បឹងជើង មៀនសោយ មេលោង កំពូលសេរី បន្ទាយមៀន និងភូមិបឹងកណ្តាល ឃុំមៀន និងភូមិបឹងកាង ស្រែមៀន ទួលឃ្លាំង ទួលមានជ័យ បាស្រី ព្រះធាតុកណ្តាល និងភូមិព្រះធាតុថ្មដា ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ ដែលមានសមាជិកសហគមន៍នេសាទសរុបចំនួន៣៤០នាក់ ប្រុស២៧៤នាក់ ស្រី៦៦នាក់ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន៣៤០គ្រួសារ។ មានគណៈកម្មការចំនួន១១នាក់ ស្រីគ្មាន និងមានក្រុមល្បាតចំនួន១០នាក់ ។

កន្លងមកសហគមន៍នេសាទនេះ បានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួនរួមមាន ៖

- បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- រៀបចំបញ្ជីឈ្មោះសមាជិកនិងគណៈកម្មការ សហគមន៍នេសាទ
- រៀបចំរចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- កំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍និងធ្វើផែនទី
- ស្នើសុំចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ទប់ស្កាត់បទល្មើសនេសាទក្នុងកន្លែងនេសាទសហគមន៍
- ការពារព្រៃលិចទឹក
- បង្កើតកន្លែងអភិរក្សត្រីមេពូជ
- ការពារកន្លែងអភិរក្សត្រីមេពូជ
- ចូលរួមសិក្ខាសាលាស្តីពីវឌ្ឍនភាពនៃដំណើរការអនុវត្តន៍ការគ្រប់គ្រងសហគមន៍នេសាទទស្សនៈកិច្ចសិក្សា
- ចូលរួមប្រជុំជាមួយភូមិ ឃុំ ស្រុក
- បង្កើតក្រុមមុខរបរ (ចិញ្ចឹមសត្វ ដាំបន្លែ ក្រុមសន្សំឥណទាន)
- ប្រមូលព័ត៌មានទូទៅសំរាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

## ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាសាស្ត្រ

ចំនួនប្រជាពលរដ្ឋសរុបក្នុងតំបន់មាន១០.២០៥នាក់ នាក់ ប្រុស៥.០០០នាក់ ស្រី៥.២០៥នាក់ក្នុងនោះមានចំនួន២.០៣៧គ្រួសារ ។ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ១០០%។

- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរចំនួន៦៨នាក់ ស្រី២៦នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន១៧០នាក់ ស្រី២៤នាក់ កម្រិតមធ្យមសិក្សាចំនួន ៨៥នាក់ ស្រី១១នាក់ និងកម្រិតឧត្តមសិក្សាចំនួន១៧នាក់ ស្រីចំនួន៩នាក់

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន៧នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន១នាក់ ស្រី០នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ២៤នាក់ ស្រី១៦នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ២នាក់ ស្រី១នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន៣នាក់ ស្រី២នាក់។

**ខ. មុខរបរ**

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេសាទនេះរួមមាន៖

| | | |
|---|---|---|
| - ធ្វើនេសាទ | ចំនួន២៥៧គ្រួសារ | |
| - ធ្វើស្រែ | ចំនួន៨៣គ្រួសារ | ទំហំ១១ហិកតា |
| - ធ្វើចំការ | ចំនួន៣៥គ្រួសារ | ទំហំ៤,៥ហិកតា |
| - ធ្វើវារីវប្បកម្ម | ចំនួន១៦គ្រួសារ | ស្រះចំនួន៦ស្រះទំហំ១៥មx២០ម x២,៥ម<br>អាងចំនួន១០អាងទំហំ២,៥មx២,៥ម x១,៥ម |
| - ដាំបន្លែ | ចំនួន៨គ្រួសារ | ទំហំ១៣មx៥០ម |
| - ជាងផ្ទះ | ចំនួន២គ្រួសារ | |
| - លក់ដូរ | ចំនួន១២គ្រួសារ | |
| - កម្មករ | ចំនួន១៥គ្រួសារ | |
| - មន្ត្រីរាជការ | ចំនួន២១គ្រួសារ | |
| - ចិញ្ចឹមសត្វ | ចំនួន៥៧គ្រួសារ | |

- ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ៨.៧៩៣.០០០រៀល ។

## ៣ កន្លែងនេសាទសហគមន៍និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

**ក. ទីតាំង**

កន្លែងនេសាទសហគមន៍បឹងក្រពិត ត្រូវលុបចេញពីអតីតឡូត៍នេសាទលេខ៩ ដែននេសាទទឹកសាបក្នុងអតីតខេត្តកំពង់ចាម មានទំហំ ៣.២៨៣ ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
- ខាងត្បូងទល់នឹងឃុំឫស្សីសាញ់និងឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង
- ខាងកើតទល់នឹងឃុំមៀន និងឃុំព្រះធាតុ
- ខាងលិចទល់នឹងឃុំពង្រ និងឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម និងឃុំល្វេនិងឃុំព្រៃដើមថ្នឹង ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង។

**ខ. ដែននេសាទ**

កន្លែងនេសាទសហគមន៍នេសាទបឹងក្រពិត មានបឹងចំនួន១១បឹង ព្រែកចំនួន០១ព្រែក និងប្រឡាយចំនួន ០១ប្រឡាយគឺ៖

| | | |
|---|---|---|
| បឹងក្រពិត | ទំហំ ៩៦៥,៧ហិកតា | ពេញមួយឆ្នាំ |
| បឹងកាង(ជាង) | ទំហំ ១០៥ ហិកតា | ពេញមួយឆ្នាំ |

| | | |
|---|---|---|
| បឹងត្រែង | ទំហំ ៦៩,៦ ហិកតា | ពេញមួយឆ្នាំ |
| បឹងខ្ចក់ | ទំហំ ១២៦ ហិកតា | ពេញមួយឆ្នាំ |
| បឹងថ្មី (ឈូក) | ទំហំ ៣ ហិកតា | ពេញមួយឆ្នាំ |
| បឹងផ្សារ | ទំហំ ៧១ ហិកតា | ពេញមួយឆ្នាំ |
| បឹងកាងទឹម | ទំហំ ២ ហិកតា | ពេញមួយឆ្នាំ |
| បឹងសន្សើមទុំ | ទំហំ ៣ ហិកតា | ពេញមួយឆ្នាំ |
| បឹងក្បាលដំរី | ទំហំ ១,៥ ហិកតា | ពេញមួយឆ្នាំ |
| បឹងកាភ្លាង | ទំហំ ៣ ហិកតា | ពេញមួយឆ្នាំ |
| បឹងតាម៉មតូចតាម៉មធំ | ទំហំ ៣ ហិកតា | ពេញមួយឆ្នាំ |
| ព្រែកអុងកូ | ទំហំ ១.២៣៤ម x៣០ម | ពេញមួយឆ្នាំ |
| ប្រឡាយមុខស្ពាន | ទំហំ ៤៥ម x ៤ម | ពេញមួយឆ្នាំ |

ដីទំនាបលិចទឹកមានទំហំសរុប ១.៩២៦,៥ ហិកតា។

**គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស**

បឹងក្រពិត ទំហំ ៣.៧២៣ម x២.៥៩៤ម ពេញមួយឆ្នាំ ។

**ឃ. ធនធានជលផល**

- ប្រភេទត្រី ៖

ត្រីរ៉ស់ ត្រីប្រា ត្រីឆ្តោរ ត្រីឆ្លាំង ត្រីកែស ត្រីក្អែក ត្រីកញ្ចុះ ត្រីលិញ ត្រីរៀល ត្រីក្រាញ់ ត្រីចង្វារ ត្រីផ្ទោង ត្រីស្លូញ ត្រីពោ ត្រីអាចម៍កុក ត្រីស្លឹកឬស្សី ត្រីកន្ត្រប់ ក្លាំងហាយ ត្រីខ្នាន់ ត្រីក្រឡង់ ត្រីសណ្តាយ ត្រីអណ្តែង ត្រីដំរី ត្រីតាអោន ត្រីក្រម៉ម ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្ទីង ត្រីអំពិលទុំ ត្រីគ្រុំ ត្រីផ្កាស្មៅ ត្រីឈ្មៀត ត្រីកញ្រ្ជូក ត្រីបណ្តូលអំពៅ ត្រីច្រកែង ត្រីកាហែ ត្រីក្រឹម ត្រីក្រឹមទន្សាយ ត្រីស្រការក្អាម ត្រីលលកសរ ត្រីឆ្កិន ត្រីបណ្តូលចេក ត្រីព្រលូង ត្រីកំពត ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ច្រាញ់ច្រាស ត្រីកំភ្លាញ ត្រីស្លាត ត្រីក្រាយ ត្រីអណ្តាតឆ្កែ ត្រីកញ្ជូនដៃ កំពិស បង្កង។

- ប្រភេទវារីសត្វ ៖

អណ្តើក ពស់ ខ្យងគូចស្រួច ខ្យងគូចទាល ខ្យងមាស(ខ្យងពណ៌លឿង) ក្តាម អន្ទង់ ខ្ចៅគូចស្រួច ខ្ចៅគូចទាល កង្កែប ឈ្លើង គ្រុំ គ្រុំចំពុះទា លៀស ។ល។

- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ៖

ដើមថ្លើមអណ្តើក ខ្លបយក្ស(អូយយ៉ាស់/បន្លាយយួន) រាំង ប្របួយមេ ប្របួយឈ្មោល ស្បាត ភ្នំភ្លែង អញ្ចាញ ត្នូ ស្មែងក្របី ធ្មេញត្រីញី ទៀនព្រៃ ត្រស់ ថ្វាង ខ្នាយមាន់ វល្លិ៍ប្រេង វល្លិ៍ទឹកដោះ វល្លិ៍ត្រដិត វល្លិ៍ដោះគន់ វល្លិ៍ត្រី វល្លិ៍ផ្អើក អំពាក់ទឹក ស្លាបទា កន្ទាំងហៃ ស្មោ ស្លត បន្លាយ្លេ ថ្វាន់ ស្នួលទឹក ច្រកែង ប្រផេញ ផ្តៅ ភ្នែកព្រាប វល្លិ៍អណ្តាតត្រកួត ក្រចាប់ សារាយសាប កំប្លោក ចកតូច ចកធំ កំពីងពួយស កំពីងពួយក្រហម ត្រកួន ព្រលិតអាចមន់មាន់ ព្រលិតដូង រំចង់ ស្តន់អំបោះ ត្រាវអណ្តែត ស្មៅអន្ទក់ទឹក ស្មៅអំពៅខៀប ចំបួង កក់ជ្រុង កក់ក្តាម ឈូក ចន្ទល់ភ្នំ(វល្លិ៍ថ្កាល់ត្រី) កញ្ឆែត ស្មៅថ្នក់ទឹក ។ល។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ ៖

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន២៥៧នាក់ ស្រី៥១នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន៣.០៦១នាក់ ស្រី៦១២នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៥០នាក់ស្រី៥នាក់។

### ខ. ឧបករណ៍នេសាទ ៖

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ២០៥ | ២០០-១.០០០ម/គ្រួសារ | ១២៣.០០០ម៉ែត្រ | ពេញមួយមួយឆ្នាំ |
| លបឬស្សី | គ្រឿង | ៣០ | ៣-៥គ្រឿង/គ្រួសារ | ១២០គ្រឿង | ខែវិច្ឆិកា ដល់ ខែមករា |
| សំណាញ់ | វង់ | ១០ | ១វង់/គ្រួសារ | ១០វង់ | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ១០០ | ៥០០-២.០០០ផ្លែ/គ្រួសារ | ១២៥.០០០ផ្លែ | ពេញមួយឆ្នាំ |
| សន្ទូចបង្កៃ | ផ្លែ | ២០០ | ១០០-២០០ផ្លែ/គ្រួសារ | ៣០.០០០ផ្លែ | ខែកក្កដា ដល់ ខែកុម្ភៈ |
| អួនអូសដៃ | វង់ | ៥០ | ៣០-១០០ម/១វង់/គ្រួសារ | ៣.២៥០ម/៥០វង់ | ខែមករា ដល់ ខែមិថុនា |
| លាន់ | គ្រឿង | ៤ | ៥០-១០០គ្រឿង/គ្រួសារ | ៣០០គ្រឿង | ខែកក្កដា ដល់ ខែមករា |
| តុមត្រីឆ្លាំង | គ្រឿង | ៤០ | ៣-៥គ្រឿង/គ្រួសារ | ១៦០គ្រឿង | ខែកក្កដា ដល់ ខែសីហា |
| កន្សំ | ដុំ | ១០០ | ១៥-២០ដុំ/គ្រួសារ | ១.៧៥០ដុំ | ខែតុលា ដល់ ខែធ្នូ |
| កង្វាត្រីឆ្លូញ | គ្រឿង | ១៥ | ១គ្រឿង/គ្រួសារ | ១៥គ្រឿង | ខែមករា ដល់ ខែឧសភា |
| ថ្នងរុញដៃ | គ្រឿង | ៥០ | ១គ្រឿង/គ្រួសារ | ៥០គ្រឿង | ខែកញ្ញា ដល់ ខែឧសភា |
| ទ្រូ | គ្រឿង | ៣០ | ៤-៥០គ្រឿង/គ្រួសារ | ៨១០គ្រឿង | ខែកក្កដា ដល់ ខែវិច្ឆិកា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ២៥៧គ្រឿង | ៣០០-១.០០០គីឡូក្រាម | ៣,៥-៨សេះ |
| ទូកអុំ និងចែវ | ១៧គ្រឿង | ៥០-១០០គីឡូក្រាម | - |

ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ១.៥៣១ | ២០០-១.០០០ម/គ្រួសារ | ៩១៨.៦០០ម៉ែត្រ | ពេញមួយមួយឆ្នាំ |
| លបឬស្សី | គ្រឿង | ១៧៦ | ៤គ្រឿង/គ្រួសារ | ៧០៤គ្រឿង | ខែវិច្ឆិកា ដល់ ខែមករា |
| សំណាញ់ | វង់ | ៤៣ | ១វង់/គ្រួសារ | ៤៣វង់ | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៥៩៦ | ៥០០-២.០០០ផ្លែ/គ្រួសារ | ៧៤៥.០០០ផ្លែ | ពេញមួយឆ្នាំ |
| សន្ទូចបង្កៃ | វង់ | ៥៨៩ | ១០០-២០០ផ្លែ/គ្រួសារ | ៨៨.៣៥០ផ្លែ | ខែកក្កដា ដល់ ខែកុម្ភៈ |

| | | | | | |
|---|---|---|---|---|---|
| អួនអូសដៃ | គ្រឿង | ១៤៥ | ៣០-១០០ម/១វង់/គ្រួសារ | ៦.៤២៥មម៉ែត្រ | ខែមករា ដល់ ខែមិថុនា |
| លាន់ | គ្រឿង | ៤៥ | ៥០-១០០គ្រឿង/គ្រួសារ | ៣.៣៧៥គ្រឿង | ខែកក្កដា ដល់ ខែមករា |
| តុមត្រីឆ្លាំង | គ្រឿង | ២២៩ | ៣-៥គ្រឿង/គ្រួសារ | ៩១៦គ្រឿង | ខែកក្កដា ដល់ ខែសីហា |
| កន្សំ | គ្រឿង | ២៩៨ | ១៥-២០ដុំ/គ្រួសារ | ៥.០៦៦ដុំ | ខែតុលា ដល់ ខែធ្នូ |
| កង្ហាត្រីឆ្លញ | គ្រឿង | ១៧៧ | ១គ្រឿង/គ្រួសារ | ១៧៧គ្រឿង | ខែមករា ដល់ ខែឧសភា |
| ថ្នងរុញដៃ | ដុំ | ២៩០ | ១គ្រឿង/គ្រួសារ | ២៩០គ្រឿង | ខែកញ្ញា ដល់ ខែឧសភា |
| ទ្រូ | គ្រឿង | ១៧៦ | ៤-៥០គ្រឿង/គ្រួសារ | ៤.៧៥២គ្រឿង | ខែកក្កដា ដល់ ខែវិច្ឆិកា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៦១២គ្រឿង | ៣០០-១.០០០គីឡូក្រាម | ៣,៥-៨សេះ |
| ទូកអុំ និងចែវ | ១៥៣គ្រឿង | ១០០-២០០គីឡូក្រាម | - |

- ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ៥០ | ២០០-១.០០០ម/គ្រួសារ | ៣០.០០០ម៉ែត្រ | ពេញមួយមួយឆ្នាំ |
| សន្ទូច | ផ្លែ | ១៩ | ១០០០ផ្លែ/គ្រួសារ | ១៩.០០០ផ្លែ | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ១៥ | ១វង់/គ្រួសារ | ១៥វង់ | ពេញមួយឆ្នាំ |
| លាន់ | គ្រឿង | ៥ | ៥០-១០០គ្រឿង/គ្រួសារ | ៣៧៥គ្រឿង | ខែកក្កដា ដល់ ខែមករា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៥០គ្រឿង | ៤០០-១.០០០គីឡូក្រាម | ៦,៥-១០ សេះ |

គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជា គក) (គ្រួសារអ្នកនេសាទ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីចំរុះ | ១១៨គីឡូក្រាម | ១១៤ គីឡូក្រាម | ២៣២គីឡូក្រាម |
| ខ្ចៅ លៀស | ៤២០ គីឡូក្រាម | - | ៤២០ គីឡូក្រាម |
| ខ្យង | - | ៣០០ គីឡូក្រាម | ៣០០ គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

**ក. ទស្សនៈវិស័យ ៖**

សហគមន៍នេសាទបឹងក្រពិត មានទស្សនៈវិស័យចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

**ខ. គោលបំណង ៖**

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុបពីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវតំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ហើយឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

**គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

**គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេង |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន (ក្នុងពេលតែមួយ) | |
| បឹងក្រពិត | តុលាដល់ឧសភា | មងរាយ | ៤០០ម/គ្រួសារ | ៤០.០០០ម៉ែត្រ/ ១០០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | មិថុនាដល់កញ្ញា | | ១០០ម/គ្រួសារ | ១០.០០០ម៉ែត្រ/ ១០០គ្រួសារ | |
| | វិច្ឆិកាដល់មករា | លបឬស្សី | ៥គ្រឿង/គ្រួសារ | ៣០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សំណាញ់ | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សន្ទូចរនង | ១០០-៣០០ផ្លែ/គ្រួសារ | ២០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | កក្កដាដល់កុម្ភៈ | សន្ទូចបង្កៃ | ៥០-៨០ផ្លែ/គ្រួសារ | ៥០គ្រួសារ | សមាជិកសហគមន៍និងអ្នក |

| | | | | | |
|---|---|---|---|---|---|
| | | | | | មិនសមាជិកសហគមន៍ |
| | មករាដល់មិថុនា | អួនអូសដៃ | ៥០ម/១វង់/គ្រួសារ | ២០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | កក្កដាដល់មករា | លាន់ | ៤០គ្រឿង/គ្រួសារ | ២០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | កក្កដាដល់សីហា | តុមត្រីឆ្លាំង | ៤គ្រឿង/គ្រួសារ | ៣៥គ្រួសារ | សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ |
| | តុលា ដល់ ធ្នូ | កន្សំ | ២០ដុំ/គ្រួសារ | ៤០គ្រួសារ | សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ |
| | មករាដល់ឧសភា | កង្វាត្រីឆ្លូញ | ១គ្រឿង/គ្រួសារ | ៥៥គ្រួសារ | សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ |
| | កញ្ញា ដល់ ឧសភា | ថ្នងរុញដៃ | ១គ្រឿង/គ្រួសារ | ៣០គ្រួសារ | សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ |
| | កក្កដាដល់វិច្ឆិកា | ទ្រូ | ១០គ្រឿង/គ្រួសារ | ៤០គ្រួសារ | សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ |
| -បឹងកាង(ជាង) ទំហំ១០៥ ហិកតា -បឹងត្រែង ទំហំ ៦៩,៦ ហិកតា -បឹងខ្ទក់ទំហំ ១២៦ ហិកតា -បឹងផ្ការទំហំ ៧១ហិកតា (ប្រើក្នុងបឹងនីមួយៗ) | តុលាដល់ឧសភា | មងរាយ | ២០០ម/គ្រួសារ | ២០.០០០ម៉ែត្រ/ ១០០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | មិថុនា ដល់ កញ្ញា | | ១០០ម/គ្រួសារ | ១០.០០០ម៉ែត្រ/ ១០០គ្រួសារ | |
| | វិច្ឆិកា ដល់ មករា | លបឫស្សី | ៤គ្រឿង/គ្រួសារ | ២០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សំណាញ់ | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ២០គ្រួសារ | សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ |
| | កក្កដា ដល់ កុម្ភៈ | សន្ទូចបង្កៃ | ៣០ផ្លែ/ គ្រួសារ | ២០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | មករា ដល់ មិថុនា | អួនអូសដៃ | ៥០ម/១វង់/គ្រួសារ | ១០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | កក្កដា ដល់ មករា | លាន់ | ៣០គ្រឿង/គ្រួសារ | ៦គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | កក្កដាដល់សីហា | តុមត្រីឆ្លាំង | ៤គ្រឿង/គ្រួសារ | ២០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | តុលា ដល់ ធ្នូ | កន្សំ | ២០ដុំ/គ្រួសារ | ១៥គ្រួសារ | សមាជិកសហគមន៍និងអ្នក |

| | | | | | |
|---|---|---|---|---|---|
| | | | | | មិនសមាជិកសហគមន៍ |
| | មករាដល់ឧសភា | កង្វាត្រីឆ្លូញ | ១គ្រឿង/គ្រួសារ | ១៥គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | កញ្ញាដល់ឧសភា | ថ្នងរុញដៃ | ១គ្រឿង/គ្រួសារ | ២០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | កក្កដា ដល់ វិច្ឆិកា | ទ្រូ | ១០គ្រឿង/គ្រួសារ | ១៥គ្រួសារ | សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ |
| -បឹងថ្មី (ឈូក) ៣ហិកតា<br>-បឹងកាងទឹម ២ហិកតា<br>-បឹងសន្សើមទុំ ៣ហិកតា<br>-បឹងក្បាលដំរី ១,៥ហិកតា<br>-បឹងកាភ្លាង ៣ហិកតា<br>-បឹងតាម៉មតូច តាម៉មធំ ៣ហិកតា<br>-ទំនាបលិចទឹកក្នុងកន្លែងនេសាទបឹងក្រពិត (ប្រើក្នុងបឹងនីមួយៗ) | ពេញមួយឆ្នាំ | មងរាយ | ៨០ម/គ្រួសារ | ១.២០០ម៉ែត្រ/ ១៥គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | វិច្ឆិកា ដល់ មករា | លបឫស្សី | ៤គ្រឿង/គ្រួសារ | ៥គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សំណាញ់ | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សន្ទូចរនង | ១០០ផ្លែ/ គ្រួសារ | ១៥គ្រួសារ | សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ |
| | កក្កដា ដល់ កុម្ភៈ | សន្ទូចបង្កៃ | ២០ផ្លែ/ គ្រួសារ | ១០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | កក្កដា ដល់ មករា | លាន់ | ២០គ្រឿង/គ្រួសារ | ៦គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | កក្កដាដល់សីហា | តុមត្រីឆ្លាំង | ៤គ្រឿង/គ្រួសារ | ១៥គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | តុលា ដល់ ធ្នូ | កន្សុំ | ១០ដុំ/គ្រួសារ | ១០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | មករាដល់ឧសភា | កង្វាត្រីឆ្លូញ | ១គ្រឿង/គ្រួសារ | ១០គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | កញ្ញាដល់ឧសភា | ថ្នងរុញដៃ | ១គ្រឿង/គ្រួសារ | ៨គ្រួសារ | សមាជិកសហគមន៍និងអ្នកមិនសមាជិកសហគមន៍ |
| | កក្កដា ដល់ វិច្ឆិកា | ទ្រូ | ៤គ្រឿង/គ្រួសារ | ១០គ្រួសារ | សមាជិកសហគមន៍ និងអ្នកមិនសមាជិកសហគមន៍ |

គ.២ ផែនការកែលម្អកន្លែងនេសាទសហគមន៍

ផែនការកែលម្អដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម - បញ្ចប់ |
|---|---|---|---|---|---|
| បឹងក្បាលដំរី | ១,៥ហិកតា | ៧០ម×៥០ម×៣ម = ១០.៥០០ម៣ | ប្រជុំផ្សព្វផ្សាយ | ២០០ | ២០១៧ - ២០១៩ |
| | | | កំណត់ទីតាំង | ១៥០ | ២០១៧ - ២០១៩ |
| | | | បោះបង្គោលព្រំបេតុង២បង្គោល | ៣០០ | ២០១៧ - ២០១៩ |
| | | | គ្រឿងចក្រស្តារឡើងវិញ | ១០.៥០០ | ២០១៧ - ២០១៩ |
| | | | អាចម៍ដីរៀបចំបង្រៀបមាត់បឹង | | |
| | | | ដាំព្រៃលិចទឹក(រាំង ត្រស់) ចំនួន ៥០ដើម | ១០០ | ២០១៧ - ២០១៩ |
| កន្លែងនេសាទសហគមន៍បឹងក្រពិត | ៣.២៨៣ ហិកតា | ៣.២៨២ហិកតា | ប្រជុំផ្សព្វផ្សាយ | ៣០០ | ២០១៧ - ២០១៩ |
| | | | កំណត់ទីតាំង | ១៥០ | ២០១៧ - ២០១៩ |
| | | | បោះបង្គោលព្រំ៦បង្គោល | ១.២០០ | ២០១៧ - ២០១៩ |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៣៣០ | ២០១៧ - ២០១៩ |
| ប្រឡាយមុខស្ពាននៅបឹងខ្នក់ | ៤៥ម× ៤ម | ១៦ម× (៤ម× ៨ម ×២ម) | ប្រជុំផ្សព្វផ្សាយ | ១០០ | ២០១៨ - ២០១៩ |
| | | | កំណត់ទីតាំង | ១៥០ | ២០១៨ - ២០១៩ |
| | | | សាងសង់ទំនប់បង្អៀរធ្វើពីបេតុង | ៦.២៥០ | ២០១៨ - ២០១៩ |
| បឹងសន្សើមទុំ | ៣ហិកតា | ១០០ម×១០០ម× ៣ម=៣០០០០ ម៣ | ប្រជុំផ្សព្វផ្សាយ | ២០០ | ២០១៨ - ២០២០ |
| | | | កំណត់ទីតាំង | ១៥០ | ២០១៨ - ២០២០ |
| | | | បោះបង្គោលព្រំបេតុង១បង្គោល និងសរសេរស្លាកសញ្ញា | ២០០ | ២០១៨ - ២០២០ |
| | | | គ្រឿងចក្រស្តារឡើងវិញ | ៣០.០០០ | ២០១៨ - ២០២០ |
| | | | អាចម៍ដីរៀបចំបង្រៀបមាត់បឹង | | |
| | | | ដាំព្រៃលិចទឹក(រាំង ត្រស់)៥០ដើម | ១០០ | ២០១៨ - ២០២០ |
| បឹងកាងទឹម | ២ហិកតា | ១០០ម×១០០ម ×៣ម=៣០០០០ ម៣ | ប្រជុំផ្សព្វផ្សាយ | ៣០០ | ២០១៩ - ២០២១ |
| | | | កំណត់ទីតាំង | ១៥០ | ២០១៩ - ២០២១ |
| | | | បោះបង្គោលព្រំបេតុង១បង្គោល និងសរសេរស្លាកសញ្ញា | ២០០ | ២០១៩ - ២០២១ |
| | | | គ្រឿងចក្រស្តារឡើងវិញ | ៣០.០០០ | ២០១៩ - ២០២១ |
| | | | អាចម៍ដីរៀបចំបង្រៀបមាត់បឹង | | |
| | | | ដាំព្រៃលិចទឹក(រាំង ត្រស់)៥០ដើម | ១០០ | ២០១៩ - ២០២១ |

### គ.៣ ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) ត្រូវអភិរក្ស | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| កន្លែងអភិរក្សត្រីមេពូជកន្លែងទ្រៀល | ៩,០៦ហិកតា | ត្រីមេពូជ | ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងការហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ (មួយលើក) | ១៥០ | ២០១៧ | ២០១៨ |
| | | | បោះបង្គោលព្រំស៊ីម៉ង់តំបន់អភិរក្សចំនួន៤បង្គោល/រៀបចំប៉មយាម | ៣.៨០០ | ២០១៧ | ២០១៨ |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៣៣០ | ២០១៧ | ២០១៨ |
| | | | យាមល្បាតការពារកន្លែងអភិរក្ស | ៣.៣៣៣ | ២០១៧ | ២០២២ |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើងវិញ ដោយដកហូតមកវិញដីព្រៃលិចទឹក ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើការពារ | សកម្មភាព | | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|---|
| តំបន់បឹងកាងរហូតដល់បឹងក្រពិត | ៦៩ ហិកតា | ព្រៃលិចទឹក | ផ្សព្វផ្សាយពីកន្លែងព្រៃលិចទឹកឱ្យបានទូលំទូលាយ | ចែកឯកសារ | ២០០ | ២០១៧ | ២០១៩ |
| តំបន់ព្រៃអូរបែកក្អម | ២៧៥ ហិកតា | | | ប្រជុំ | ៥៦២ | | |
| | | | បោះបង្គោលព្រំព្រៃលិចទឹកចំនួន៦បង្គោលនិងសរសេរស្លាកសញ្ញា២ស្លាក | | ១.០០០ | ២០១៧ | ២០១៩ |
| | | | ថែរក្សា ការពារ | | ៩០០ | ២០១៧ | ២០២២ |

### គ៥-ផែនការទប់ស្កាត់បទល្មើសជលផល

ផែនការចុះទប់ស្កាត់បទល្មើសជលផលត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ<br>-ផ្សព្វផ្សាយតាមមេក្រូ ៣ថ្ងៃ/ឆ្នាំ<br>-ផ្សព្វផ្សាយបិទឯកសារ១ដង/ឆ្នាំ<br>-ប្រជុំផ្សព្វផ្សាយ១ដង/ឆ្នាំ មិថុនា/រៀងរាល់ឆ្នាំ | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទ និងសារៈសំខាន់នៃធនធានជលផល<br>-មានការយល់ដឹងពីការគ្រប់គ្រងសហគមន៍នេសាទ | ១.៥៦០ | គណៈកម្មការសមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ | ២០១៧ | ២០២២ |

| | | | | | |
|---|---|---|---|---|---|
| | -ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ | | | | |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការដើម្បីចុះអនុវត្តន៍ តាមស្ថានភាពជាក់ស្តែង | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ<br>-មានផែនការសមស្របជាក់លាក់ដើម្បីចុះអនុវត្តការងារ | ១៦៥<br>(២ដង/ឆ្នាំ) | គណៈកម្មការសមាជិកស.នអាជ្ញាធរមូលដ្ឋានអង្គភាពពាក់ព័ន្ធ | ២០១៧ | ២០២២ |
| អនុវត្តផែនការៈ<br>(រៀបចំកំលាំងចុះ បង្ក្រាបដល់ទីកន្លែងដោយទំនាក់ទំនង និងសហការជាមួយអាជ្ញាធរមូលដ្ឋានអង្គភាពពាក់ព័ន្ធ<br>និងអង្គការដៃគូ) (៤ដង/ខែ = ២០០ដង)ជាប្រចាំ<br>លើកលែងខែមិថុនា-កក្កដា | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកស.នធូរធារ | ១៤.៤០០ | គណៈកម្មការសមាជិកស.នអាជ្ញាធរមូលដ្ឋានជំនាញជលផលស្ថាប័នពាក់ព័ន្ធ | ២០១៧ | ២០២២ |
| យុទ្ធនាការបង្ក្រាបបទល្មើសនេសាទ | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកស.នធូរធារ | ៩.៩៥៦<br>(២ខែ/ឆ្នាំ) | គណៈកម្មការសមាជិកស.នអាជ្ញាធរមូលដ្ឋានជំនាញជលផលស្ថាប័នពាក់ព័ន្ធ | មិថុនា-កក្កដា/២០១៧ | មិថុនា-កក្កដា/២០២១ |
| | ប្រេងសាំងនិងប្រេងបាត | ៩៦០<br>(២០លីត្រ/ថ្ងៃ) | | | |
| មធ្យោបាយនិងសម្ភារៈ<br>-សាំង និងប្រេងបាត<br>-អាវភ្លៀង អាវពោង ពិល មួក<br>-កាតទូរស័ព្ទ អាយកូមទាក់ទង<br>-ម៉ាស៊ីនថត កែវយឺត | មានលទ្ធភាពចុះល្បាតដោយមានប្រសិទ្ធិភាព | ៣.៣៤៦ | គណៈកម្មការសមាជិកស.នអាជ្ញាធរមូលដ្ឋានជំនាញជលផលស្ថាប័នពាក់ព័ន្ធអង្គការដៃគូ | ២០១៧ | ២០២២ |
| ទិញទូកស្ពាច់និងម៉ាស៊ីនថ្មីចំនួន១គ្រឿង | មានមធ្យោបាយចុះល្បាត | ១.៥០០ | គណៈកម្មការសមាជិកស.នអាជ្ញាធរមូលដ្ឋានជំនាញជលផលស្ថាប័នពាក់ព័ន្ធអង្គការដៃគូ | ២០១៨ | ២០១៨ |

គ៦-ផែនការប្រជុំប្រចាំខែនិងសម្ភារៈអនុវត្តការងាររបស់គណៈកម្មការសហគមន៍នេសាទ

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំគណៈកម្មការសហគមន៍នេសាទ សប្តាហ៍ទី៣នៃខែ/រៀងរាល់ខែ | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-មានផែនការណ៍អនុវត្តន៍បន្ត | ១.១០០ | -គណៈកម្មការ<br>-ក្រុមល្បាត | ២០១៧ | ២០២២ |
| ប្រជុំជាមួយអាជ្ញាធរឃុំឬស្ថាប័នពាក់ព័ន្ធ (២០-២៦/រៀងរាល់ខែ) | -ទទួលព័ត៌មាន និងផ្តល់របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-បញ្ចូលផែនការណ៍ជាមួយផែនការអភិវឌ្ឍន៍ឃុំនិងផែនការស្ថាប័នពាក់ព័ន្ធ | ៩០០ | -អាជ្ញាធរឃុំ<br>-គណៈកម្មការ<br>-ស្ថាប័នពាក់ព័ន្ធ | ២០១៧ | ២០២២ |
| -សម្ភារៈការិយាល័យ<br>-ទិញក្រដាស់ ប៊ិច<br>-ព្រីនឯកសារ<br>-ការទំនាក់ទំនង | មានសម្ភារៈការិយាល័យសម្រាប់ប្រើប្រាស់ | ៥០០ | គណៈកម្មការ | រយៈពេល៥ឆ្នាំ | |

គ៧-ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាលត្រូវបានរៀបចំឡើង ដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ ដូចមានខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការផ្សព្វផ្សាយ | | | | | |
| ប្រជុំផ្សព្វផ្សាយស្តីពីច្បាប់<br>-ជលផល ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងស.ន<br>-លក្ខន្តិកៈបទបញ្ជាផ្ទៃក្នុងស.ន ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍<br>-ការប្រើប្រាស់និងការទុកដាក់ថ្នាំកសិកម្ម និង<br>-បទពិសោធន៍ដែលទទួលបាន | -សមាជិកសហគមន៍នេសាទ និងអ្នកខាងក្រៅមានការយល់ដឹង និងអនុវត្តតាម<br>-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការនិងវិធានច្បាប់នានាដែលបានផ្សព្វផ្សាយ<br>-ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឲ្យជីវភាពធូរធារ | ២.០៦៤ | គណៈកម្មការ,សមាជិកស.ននិងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល, អង្គការដៃគូរ | មេសា-មិថុនា/រៀងរាល់ឆ្នាំ | |
| -ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ | -ការរស់នៅមានសុវត្ថិភាព និងគ្មានអំពើក្នុងគ្រួសារ | ៤៥០ | | មិថុនា ២០១៧ | មិថុនា ២០២១ |

| | | | | | |
|---|---|---|---|---|---|
| -ចែកចាយឯកសារនានា<br>បិទផ្សាយឯកសារ ១ដង/ឆ្នាំ | | ១៦០ | | ២០១៧ | ២០២២ |
| ផ្សព្វផ្សាយជ្រើសរើសក្រុមយុវជនសហគមន៍នេសាទបឹងក្រពិត | មានយុវជនចូលរួមក្នុងការងារគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ | ៨០០ | សមាជិកសហគមន៍នេសាទ | ២០១៧ | ២០១៨ |
| ផែនការបណ្តុះបណ្តាល | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល :<br>-របាយការណ៍<br>-កំណត់ហេតុ<br>-គម្រោងស្នើសុំថវិកា<br>-គម្រោងថវិកានិងការគ្រប់គ្រងថវិកាស.ន | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ អ្នកពាក់ព័ន្ធ សិស្ស និស្សិត បានយល់ដឹង និងអាចអនុវត្តបានក្នុងការងារជាក់ស្តែង | ១.៤០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន អ្នកពាក់ព័ន្ធ សិស្ស,និស្សិត | ២០១៧ | ២០១៨ |
| វគ្គបណ្តុះបណ្តាលពីការប្រើប្រាស់កំព្យូទ័រ | គណៈសហគមន៍នេសាទ (២នាក់) | ៣២៥ | គណៈកម្មការ ស.ន | ២០១៨ | ២០១៨ |
| វគ្គបណ្តុះបណ្តាលយេនឌ័រ និងការវិភាគយេនឌ័រ | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តបាន ក្នុងការងារជាក់ស្តែង | ៤០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | ២០១៨ | ២០១៨ |
| វគ្គបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុ | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តបាន ក្នុងការងារជាក់ស្តែង | ៥០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | ២០១៩ | ២០១៩ |
| វគ្គបណ្តុះបណ្តាលពី៖<br>-ការគ្រប់គ្រងនិងសារៈសំខាន់នៃធនធានធម្មជាតិ<br>-សិទ្ធិជាមូលដ្ឋានលើធនធានធម្មជាតិ | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តបាន ក្នុងការងារជាក់ស្តែង | ៦៥០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | ២០២០ | ២០២១ |

គ៨- ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ

ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការបណ្តុះបណ្តាល | | | | | |
| បច្ចេកទេសដាំបន្លែ | មានមុខរបរបង្កើនប្រាក់ចំណូល | ៨០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០១៨ |
| កែច្នៃផលផលិតផលជលផល | មានមុខរបរបង្កើនប្រាក់ចំណូល | ១.៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០១៨ |
| ចិញ្ចឹម (ត្រី កង្កែប អន្ទង់) | មានមុខរបរបង្កើនប្រាក់ចំណូល | ១.៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០១៨ |
| កែច្នៃសម្ភារៈប្រើប្រាស់ពីកំប្លោកនិងកក់ | មានមុខរបរបង្កើនប្រាក់ចំណូល | ១.០០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ជំនាញវិជ្ជាជីវៈលើការផ្តល់សេវាទស្សនាកំសាន្ត | -ក្រុមចុងភៅ<br>-ក្រុមផ្ទះស្នាក់នៅ<br>-ក្រុមដឹកជញ្ជូន<br>-ក្រុមផ្ញើរយានយន្ត<br>-ក្រុមផ្គត់ផ្គង់ផលិតផលកសិកម្ម<br>-ក្រុមរោងលម្ហែ (កញ្ជះ) | ១.០០០ | គណៈកម្មការនិងសមាជិស.ន | ២០១៨ | ២០១៩ |
| ទស្សនៈកិច្ចសិក្សា | | ២.៥០០ | គណៈកម្មការនិងសមាជិស.ន | ២០១៨ | ២០១៩ |
| ផែនការបង្កើតក្រុមមុខរបរ | | | | | |
| ក្រុមកែច្នៃផលិតផលជលផល | គណៈសហគមន៍និងសមាជិកនេសាទបង្កើតឡើងជាក់ស្តែង<br>-មានផលិតផលជលផលផ្គត់ផ្គង់តំបន់ទស្សនាកំសាន្តនិងទីផ្សារ<br>- មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ក្រុមដាំបន្លែ | -គណៈសហគមន៍និងសមាជិកនេសាទបង្កើតឡើងជាក់ស្តែង<br>-មានបន្លែផ្គត់ផ្គង់ដល់តំបន់ទស្សនាកំសាន្ត និងទីផ្សារ<br>- មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ក្រុមកែច្នៃសម្ភារៈប្រើប្រាស់ពីកំប្លោកនិងកក់ | គណៈសហគមន៍និងសមាជិកនេសាទបង្កើតឡើងជាក់ស្តែង<br>-មានសម្ភារៈកែច្នៃផ្គត់ផ្គង់ដល់តំបន់ទស្សនាកំសាន្ត និងទីផ្សារ<br>- មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |

គ៩- ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងសហគមន៍នេសាទ

ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងសហគមន៍នេសាទបឹងក្រពិត ត្រូវបានរៀបចំឡើងនៅតំបន់បឹងក្រពិត ចំណុចថ្មសំលៀង មានដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំផ្សព្វផ្សាយ<br>-លើកដំបូង<br>-ដំណើរការរួច | គណៈសហគមន៍នេសាទ សមាជិកស.ន បានយល់ដឹង និងអាចអនុវត្តបាន ក្នុងការងារជាក់ស្តែង | ១.១០០ | -គណៈកម្មការ និងសមាជិកស.ន<br>-អាជ្ញាធរពាក់ព័ន្ធ<br>-ជំនាញជលផល<br>-ប៉ូលីស | ២០១៧ | ២០១៨ |
| ទស្សនៈកិច្ចសិក្សា | មានបទពិសោធន៍ស្តីពីការរៀបចំកន្លែងទស្សនាកំសាន្ត | ១.០៣៥ | -គណៈកម្មការ<br>-អាជ្ញាធរពាក់ព័ន្ធ<br>-ជំនាញជលផល | ២០១៧ | ២០១៨ |
| រៀបចំទីតាំងទស្សនាកំសាន្ត<br>- ស្លាកសញ្ញាទីតាំងចំនួន១<br>-ដាំដើមឈើចំនួន១០០ដើម<br>-សាងសង់រោងប្រជុំ<br>រោងលម្ហែចំនួន១២<br>-ទូកដឹកជញ្ជូនភ្ញៀវចំនួន៤<br>-បង្គន់អនាម័យ/ធុងសម្រាម<br>-បណ្តាញអគ្គិសនី<br>-ផលិតសៀវភៅណែនាំ | -ដំណើរការបង្កើតតំបន់ទស្សនាកំសាន្តទទួលបានជោគជ័យ<br>-មានសេវាល្អ ធានាគុណភាព តម្លៃសមរម្យ<br>-មានភ្ញៀវគាំទ្រ | ១២.៩០០ | គណៈកម្មការ | ២០១៨ | ២០២១ |
| បង្កើតក្រុម | -ក្រុមបដិសណ្ឋារកិច្ច<br>-ក្រុមសេវាម្ហូបអាហារ<br>-ក្រុមរោងសម្រាកលម្ហែ<br>-ក្រុមផ្ទះស្នាក់នៅ<br>-ក្រុមអាវពោងហែលទឹក<br>-ក្រុមដឹកជញ្ជូន<br>-ក្រុមផ្ញើរយានយន្ត<br>-ក្រុមផ្គត់ផ្គង់ផលិតផលកសិកម្ម<br>-ក្រុមលក់ផលិតផលកែច្នៃ<br>-ក្រុមកសិកម្មបង្ហាញដើម្បីទេសភាព | ១.២០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០២១ |
| ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងរបស់ក្រុមមុខរបរ | មានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមនីមួយៗក្នុងការអនុវត្ត | ៨០០ | គណៈកម្មការ និងសមាជិកស.ន | ២០១៨ | ២០២១ |
| សន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ | ធានាសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យក្នុងតំបន់ទស្សនាកំសាន្ត | ១២០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០២១ |

គ១០- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ

ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ ជ្រើសរើសសមាជិកក្រុមឥណទានប្រេងម៉ាស៊ូត | ក្រុមឥណទានសហគមន៍នេសាទបឹងក្រពិត ត្រូវបានបង្កើតឡើងនៃគណៈកម្មការនិងសមាជិកស.ន | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០១៧ |
| ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងក្រុមឥណទានប្រេងម៉ាស៊ូត | -មានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមឥណទានប្រេងម៉ាស៊ូត<br>-មានដំណើរការល្អ (ខ្ចី សង) | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០១៧ |
| ផ្ដល់ឥណទាននិងប្រមូលបដិភាគប្រេងម៉ាស៊ូត | មានក្រុមឥណទានប្រេងម៉ាស៊ូតដើម្បីបង្កើនមុខរបរ | ២.០០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៧ | ២០១៧ |
| ប្រជុំប្រចាំខែក្រុមឥណទានប្រេងម៉ាស៊ូត | -របាយការណ៍ឥណទាន<br>-ការរីកចម្រើននូវមុខរបរ | ២៧០ | ក្រុមឥណទានប្រេងម៉ាស៊ូត | ២០១៧ | ២០២២ |

គ១១-ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ

ផែនការសម្រាប់អភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ប៉ាន់ស្មានតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីតាមស្រះ (៦គ្រួសារ) | ៣សx១៥មx២០មx២,៥ម | ត្រីអណ្ដែង | ៥.០០០ កូន/ឆ្នាំ | ៧៨៧,៥ (១ក=៧០រៀល) | មិថុនា/ ២០១៨ | ខែកុម្ភៈ/ ២០២១ |
| | ៣សx១៥មx២០មx២,៥ម | ត្រីប្រា ឆ្ពិន ទីឡាព្យ៉ា | ៥.០០០ កូន/ឆ្នាំ | ៧៨៧,៥ (១ក=៧០រៀល) | មិថុនា/ ២០១៨ | ខែកុម្ភៈ/ ២០២១ |
| ចិញ្ចឹមកង្កែប អន្ទង់តាមអាង (១០គ្រួសារ) | ៥អx២មx១,៥មx១,២ម | អន្ទង់ | | ៦២៥ | ខែធ្នូ/ ២០១៨ | ខែមេសា/ ២០២១ |
| | ៥អx២មx១,៥មx១,២ម | កង្កែប | | ៥០០ | ខែធ្នូ/ ២០១៨ | ខែមេសា/ ២០២១ |
| ការចិញ្ចឹមត្រីតាមបឹងធម្មជាតិក្នុងបឹងឈូករបស់ស.នបឹងក្រពិត | ៨ហិកតា | ចំរុះ រ៉ស់ កំភ្លាញ ប្រា អណ្ដែង ឆ្ពិន ក្រាញ់ កន្ធ្រប់ ឆ្ពិន | ៥០០គីឡូ | ១.២៥០ | ២០១៨ | ២០២១ |

## គ១២- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ

ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទនៅខាងជើងទន្លេវ៉ៃគោចំណុចពោងអ្នកតា (៤០ម៉ែត្រ×៥០ម៉ែត្រ) ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| សាងសង់ស្នាក់ការសហគន៍នេសាទ ទំហំ៦ម×៨ម ធ្វើពីគ្រឿងឈើ ប្រក់ស័ង្កសី ដោយមានបង្គន់អនាម័យ | - សហគមន៍នេសាទមានការិយាល័យសម្រាប់ធ្វើការ<br>-មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រង កន្លែងនេសាទសហគមន៍ | ៦.៥០០ | គណៈកម្មការសមាជិកស.ន ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០១៨ | ២០១៩ |
| បណ្តាញអគ្គីសនី | មានថាមពលអគ្គីសនីសម្រាប់ស.នធ្វើការងារ | ១០០ | | ២០១៨ | ២០១៩ |
| សម្ភារៈសហគមន៍នេសាទ (តុ ទូ ក្តារខៀន កៅអី កំព្យូទ័រ ព្រីនធើ) | មានសម្ភារៈសម្រាប់ស.នធ្វើការ | ១.០៥០ | | ២០១៨ | ២០១៩ |

## គ១៣-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ ចាប់បញ្ចប់ | ចំណូល ដុល្លា | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានសមាជិកភាព សហគមន៍នេសាទ | -ផ្សព្វផ្សាយការចូលជាសមាជិកនិងបង់ប្រាក់សមាជិកភាព<br>-ប្រមូលភាគទាន ១០.០០០រៀល/ម្នាក់ | ២០១៧ | ២០២២ | ៨៥០ | ១០.០០០រៀល/នាក់ (៣៤០នាក់) |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំ១០៦៦,២៥ | ២០១៧ | ២០២២ | ២.១៩១ | -អ្នកមិននេសាទ ៨៣ នាក់១.០០០រៀល/ម្នាក់<br>-អ្នកនេសាទជាប្រចាំ៧៧ នាក់១០.០០០រៀល/ម្នាក់<br>-អ្នកនេសាទម្តងម្កាល១៨០ ៥.០០០រៀល/ម្នាក់ |
| កម្រៃអ្នកនេសាទមិនមែនជាសមាជិកនិងអ្នកមកពីក្រៅ | -ផ្សព្វផ្សាយជូនដំណឹង<br>-ប្រមូលប្រាក់កម្រៃពីអ្នកនេសាទមិនមែនជាសមាជិកនិងអ្នកមកពីក្រៅ ៥%នៃ ៣.១១១នាក់ | ២០១៧ | ២០២២ | ៣.៨៧៥ | អ្នកនេសាទមិនមែនជាសមាជិកនិងអ្នកមកពីក្រៅចំនួន ១៥៥នាក់×២០.០០០រៀល |

| | | | | | |
|---|---|---|---|---|---|
| សរសេរគម្រោងស្នើសុំថវិកាពី ៖<br>-រាជរដ្ឋាភិបាល<br>-សប្បុរសជន<br>-អង្គការដៃគូរពាក់ព័ន្ធ | -ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធនិងអង្គការដៃគូរ<br>-សរសេរគម្រោងស្នើសុំថវិកានិងតាមដាន | ២០១៧ | ២០២២ | ១៦៧.៩៥០ | សរសេរគម្រោងស្នើសុំថវិកាចំណាយ ៥០០ដុល្លា |
| សរុប | | | | ១៧៤.៣៦៦ | |

## ឃ. ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការរួមមាន សមាជិកគណៈកម្មការសហគមន៍នេសាទចាស់ទុំ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗ ជាពិសេសបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទង និងបច្ចេកទេសជលផល ដូចជាការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារបឹង ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោងនិងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្របច្ចេកទេសនិងថវិការសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំនិងអនុវត្តន៍ផែនការ តាមដំណាក់កាលនីមួយៗ ដោយជាក់លាក់និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលនិងស្ថាប័នពាក់ព័ន្ធ ដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការ គ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តន៍ផែនការ
- ធ្វើសមាហរណកម្មបញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំនិងស្ថាប័នពាក់ព័ន្ធ
- រៀបចំធ្វើស្នាក់ការសហគមន៍នេសាទចំនួនមួយខ្នងនិងទិញទូកម៉ាស៊ីនចំនួន១គ្រឿងសម្រាប់គ្រប់គ្រងនិងថែរក្សា ការពារកន្លែងនេសាទសហគមន៍ ។

តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**ចិនក្រពិត** រយៈពេល ៥ ឆ្នាំ (២០១៧ ដល់ ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ធ្វើនេសាទ | -មាននិរន្តរភាពធនធាន<br>-បង្កើនប្រាក់ចំណូល | | សមាជិកនិងគណៈកម្មការ | ២០១៧ | ២០២២ | |
| គ២.ផែនការកែលម្អកន្លែងនេសាទសហគមន៍ | -ស្វែងរកម្ចាស់ជំនួយ<br>-ប្រជុំផ្សព្វផ្សាយ/កំណត់ទីតាំង<br>-គ្រៀងចក្រស្តារប្រឡាយ<br>-អាចម៍ដីរៀបចំតាមមាត់បឹង<br>-បោះបង្គោលព្រំបេតុង/ដាក់ស្លាក<br>-សាងសង់ទំនប់បង្វៀរធ្វើពីបេតុង<br>-ដាំព្រៃលិចទឹក រាំង ត្រស់ | -ត្រីមានទីជម្រក<br>-ព្រៃលិចទឹកបានគង់វង្ស<br>-ត្រីកើន<br>-មានទឹកប្រើប្រាស់ | ៨១.១៣០ | - ស.ន.ប.ក.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០១៩ | |
| | | | | | ២០១៨ | ២០១៩ | |
| | | | | | ២០១៨ | ២០២០ | |
| | | | | | ២០១៩ | ២០២១ | |
| គ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | -ផ្សព្វផ្សាយឱ្យបានទូលំទូលាយ<br>- បោះបង្គោលព្រំស៊ីម៉ង់តំបន់អភិរក្ស<br>-ដាក់ស្លាកសញ្ញា<br>-សាងសង់ប៉មយាម | -មានត្រីមេពូជ<br>-ត្រីកើនឡើងវិញ | ៤.២៨០ | - ស.ន.ប.ក.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០១៨ | |
| | យាមល្បាត ការពារ | | ៣.៣៣៣ | | ២០១៧ | ២០២២ | |
| គ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | ផ្សព្វផ្សាយឱ្យបានទូលំទូលាយ (ចែកឯកសារនិងប្រជុំ) | -ព្រៃលិចទឹកបានគង់វង្ស<br>-ជាជម្រកត្រី កន្លែងត្រីពងកូននិងរកចំណី | ៧៦២ | - ស.ន.ប.ក.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០១៩ | |
| | បោះបង្គោលព្រំព្រៃនិងសរសេរស្លាកសញ្ញាតាមបង្គោល | | ១.០០០ | | | | |
| | ថែរក្សា ការពារ | | ៨០០ | | ២០១៧ | ២០២២ | |
| គ៥.ផែនការទប់ស្កាត់បទល្មើសជលផល | -ប្រជុំផ្សព្វផ្សាយ<br>-ប្រជុំរៀបចំផែនការល្បាត<br>-អនុវត្តផែនការចុះបង្ក្រាបដល់ទីកន្លែង | -បទល្មើសថយចុះ<br>-ធនធានព្រៃលិចទឹកនិងត្រីកើនឡើងវិញ<br>-ផលចាប់ត្រីបានច្រើន | ១៦.១២៥ | - ស.ន.ប.ក.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០២២ | |
| | យុទ្ធនាការបង្ក្រាបបទល្មើសជលផល | | ១០.៩១៦ | | ២០១៧ | ២០២១ | |
| | ទិញទូកស្ទាច់និងម៉ាស៊ីនថ្មី | មានមធ្យោបាយល្បាត | ១.៥០០ | | ២០១៨ | ២០១៨ | |
| | ទិញមធ្យោបាយនិងសម្ភារៈប្រើប្រាស់ | មានសម្ភារៈល្បាត | ៣.៣៤៦ | | ២០១៧ | ២០២១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៦.ផែនការប្រជុំប្រចាំខែ និងទិញសម្ភារៈអនុវត្តន៍ការងារគណៈកម្មការស.ន | -ប្រជុំ<br>-ទិញសម្ភារៈការិយាល័យ | -របាយការណ៍លទ្ធផលសម្រេចបានប្រចាំខែ<br>-មានសម្ភារៈការិយាល័យសម្រាប់ប្រើប្រាស់ | ២.៨០០ | - ស.ន.ប.ក.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០២២ | |
| គ៧.ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល | ផ្សព្វផ្សាយ (ប្រជុំ បិទផ្សាយ ចែកឯកសារ)៖ ជលផល, ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងស.ន,ផែនការគ្រប់គ្រងស.ន, ការប្រើប្រាស់និងការទុកដាក់ថ្នាំកសិកម្ម និងបទពិសោធន៍នានាដែលទទួលបាន | -គណៈកម្មការសមាជិកសហគមន៍នេសាទនិងប្រជាពលរដ្ឋមានការយល់ដឹង<br>-មានយុវជនចូលរួមក្នុងការងារសហគមន៍នេសាទ<br>-អាចយកទៅអនុវត្តន៍បាន | ២.៦៧៤ | - ស.ន.ប.ក.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០២២ | |
| | ជ្រើសរើសក្រុមយុវជនចូលរួមសហគមន៍នេសាទបឹងក្រពិត | | ៨០០ | | ២០១៧ | ២០១៨ | |
| | បណ្តុះបណ្តាលស្តីពី៖<br>-របាយការណ៍ កំណត់ហេតុ<br>-គម្រោងស្នើសុំនិងការគ្រប់គ្រងថវិកា<br>-ការប្រើប្រាស់កំព្យូទ័រ<br>-ការប្រែប្រួលអាកាសធាតុ<br>-យេនឌ័រ និងការវិភាគយេនឌ័រ<br>-ការគ្រប់គ្រងនិងសារៈសំខាន់នៃធនធានធម្មជាតិ<br>-សិទ្ធិជាមូលដ្ឋាននលើធនធានធម្មជាតិ | | ៣.២៧៥ | | ២០១៧ | ២០២១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៨.ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍ | បណ្ដុះបណ្ដាលស្ដីពីៈ<br>-បច្ចេកទេសដាំបន្លែ<br>-កែច្នៃផលនេសាទ<br>-ចិញ្ចឹម( ត្រី អន្ទង់ កង្កែប)<br>-កែច្នៃសម្ភារៈប្រើប្រាស់ពីកំប្លោក<br>-ជំនាញផ្ដល់សេវាទស្សនាកំសាន្ដ<br>-ទស្សនៈកិច្ចសិក្សា | -មានចំណេះដឹងនិងបច្ចេកទេសលើមុខរបរ<br>-អាចអនុវត្តន៍បានក្នុងការប្រកបមុខរបរ | ៨.៣០០ | - ស.ន.ប.ក.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០១៩ | |
| | បង្កើតក្រុមមុខរបរៈ<br>ក្រុមចិញ្ចឹមត្រី អន្ទង់ កង្កែបនិងក្រុមដាំបន្លែឬដំណាំចំការ | -មានក្រុមមុខរបរកើតឡើង<br>-មានផលិតផលផ្គត់ផ្គង់ទីផ្សារ<br>-លើកស្ទួយកម្រិតជីវភាព | ១.៥០០ | - ស.ន.ប.ក.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ | ២០១៨ | ២០១៩ | |
| គ៩.ផែនការបង្កើតកន្លែងទស្សនាកំសាន្ដ | -ផ្សព្វផ្សាយឱ្យបានទូលំទូលាយ<br>-រៀបចំទីតាំងទស្សនាកំសាន្ដ<br>-បង្កើតក្រុមមុខរបរ<br>-ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងនៃក្រុម<br>-សន្ដិសុខ សណ្ដាប់ធ្នាប់ និងអនាម័យ | -ប្រភពចំណូលដល់សហគមន៍នេសាទ<br>-បង្កើតមុខរបរដល់សមាជិកសហគមន៍នេសាទ<br>-មានភ្ញៀវមកកំសាន្ដ | ១៧.១៥៥ | - ស.ន.ប.ក.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០២១ | |
| គ១០.ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ | -ផ្សព្វផ្សាយជ្រើសរើសអ្នកស្ម័គ្រចិត្ត<br>-បង្កើតក្រុមឥណទានប្រេងម៉ាស៊ូតនិងក្រុមឥណទានប្រាក់សន្សំ<br>-រៀបចំរចនាសម្ព័ន្ធក្រុមឥណទាន<br>-ប្រជុំរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង<br>-ផ្ដល់ទុនតម្កល់និងចូលរួមបដិភាគ | -មានក្រុមឥណទាន<br>-មានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមឥណទាន<br>-មានដំណើរការល្អ(ខ្ចី សង)<br>មានទុនចាប់ផ្ដើមមុខរបរ<br>-របាយការណ៍ឥណទាន<br>-ការរីកចម្រើននូវមុខរបរ | ៣.២៧០ | - ស.ន.ប.ក.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០១៨ | |
| | ប្រជុំប្រចាំខែ | | | | ២០១៧ | ២០២២ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ១១.នការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ | -ចិញ្ចឹមត្រីតាមស្រះ<br>-ចិញ្ចឹមកង្កែបនិងអន្ទង់តាមអាង<br>-ចិញ្ចឹមត្រីតាមបឹងធម្មជាតិ<br>-ទិញពូជ | -បង្កើតមុខរបរដល់សមាជិកសហគមន៍នេសាទ<br>-មានផលិតផលផ្គត់ផ្គង់ទីផ្សារ<br>-លើកស្ទួយកម្រិតជីវភាព | ៣.៩៥០ | - ស.ន.ប.ក.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៨ | ២០២១ | |
| គ១២.ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទបឹងក្រពិត | -សាងសង់ស្នាក់ការស.ន<br>-រៀបចំបណ្តាញអគ្គីសនី<br>-ទិញសម្ភារៈ | - សហគមន៍នេសាទមានកន្លែងសម្រាប់ធ្វើការងារស.ន<br>-មានថាមពលអគ្គីសនីសម្រាប់ស.នធ្វើការងារ<br>-មានសម្ភារៈប្រើប្រាស់<br>-សម្រេចបានសកម្មភាពការងារ | ៧.៦៥០ | - ស.ន.ប.ក.ព<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| គ១៣.ផែនការថវិកាទ្រទ្រង់សហគមន៍នេសាទ | -ប្រមូលភាគទានសមាជិកភាព<br>- ភាគទានប្រចាំឆ្នាំ<br>- កម្រៃពីអ្នកខាងក្រៅ<br>- សរសេរគម្រោងស្នើសុំស្ថាប័ននានាក្នុងខេត្ត សប្បុរសជន អង្គការដៃគូ | មានថវិកាអនុវត្តន៍សកម្មភាពគ្រប់គ្រងសហគមន៍នេសាទ | ១៧.៣៦៦ | - រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៧ | ២០២២ | |

| សកម្មភាព | ២០១៧ | | | ២០១៨ | | | ២០១៩ | | | ២០២០ | | | ២០២១ | | | ២០២២ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | មិថុនា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | ... | ឧសភា |
| គ១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | |
| គ២.ផែនការកែលម្អកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | |
| គ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | |
| គ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | |
| គ៥.ផែនការទប់ស្កាត់បទល្មើសជលផល | | | | | | | | | | | | | | | | | | |
| គ៦.ផែនការប្រជុំប្រចាំខែនិងទិញសម្ភារៈការិយាល័យ | | | | | | | | | | | | | | | | | | |
| គ៧.ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល | | | | | | | | | | | | | | | | | | |
| គ៨.ផែនការបង្កើតមុខរបរសមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | |
| គ៩.ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងស.ន | | | | | | | | | | | | | | | | | | |
| គ១០.ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ | | | | | | | | | | | | | | | | | | |
| គ១១.ផែនការអភិវឌ្ឍន៍វារីវប្បកម្មសហគមន៍នេសាទ | | | | | | | | | | | | | | | | | | |
| គ១២.ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ | | | | | | | | | | | | | | | | | | |
| គ១៣.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | | | | | | | |

សូមគោរពជូន
លោកមេឃុំពាក់ព័ន្ធ
"ដើម្បីជូនពិនិត្យនិងសម្រួល"
ចុះឈ្មោះ..ថ្ងៃទី..២៣....ខែ..មីនា......ឆ្នាំ២០១៧
ប្រធានគណៈកម្មការសហគមន៍នេសាទ
បឹងក្រពិត

លេខ...........
បានឃើញនិងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ
"ដើម្បីជូនពិនិត្យនិងសម្រួល"
មៀន ថ្ងៃទី...........ខែ..មីនា......ឆ្នាំ២០១៧
មេឃុំមៀន

លេខ...........
ព្រះធាតុ ថ្ងៃទី..៣០.....ខែ..មីនា.....ឆ្នាំ២០១៧
មេឃុំព្រះធាតុ

លេខ..............ជជ

បានឃើញនិងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី២៣... ខែ.......ឆ្នាំ២០១៧

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**

លេខ..........................

បានឃើញនិងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ"

ត្បូងឃ្មុំ ថ្ងៃទី.៣១.....ខែ..........ឆ្នាំ២០១៧

ប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំ

**ហេង ពិសិដ្ឋ**

លេខ.......................

បានឃើញនិងគោរពជូន

លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ខេត្តត្បូងឃ្មុំ

"ដើម្បីជូនពិនិត្យនិងសម្រួល"

ត្បូងឃ្មុំ ថ្ងៃទី...........ខែ..........ឆ្នាំ២០១៧

នាយខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ

**អៀម_ម៉ាយុំនី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារផ្សេងៗ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | បឹងក្រពិត |
| ភូមិ | ៖ | កន្លែងចក ស្វាយពក ថ្មសំលៀង បឹងជើង ថ្មីសោយ មៀន បន្ទាយមៀន បឹងកណ្ដាល កំពូលសេរី និងមេលោង |
| ឃុំ | ៖ | មៀន |
| ភូមិ | ៖ | ស្រែមៀន ទួលឃ្លាំង ទួលមានជ័យ បាស្រី បឹងកាង ព្រះធាតុកណ្ដាល និងព្រះធាតុថ្មដា |
| ឃុំ | ៖ | ព្រះធាតុ |
| ស្រុក | ៖ | អូររាំងឪ |
| ខេត្ត | ៖ | ត្បូងឃ្មុំ |

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ

លេខៈ...០៤២......ន.អ.ស

**សូមគោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**កម្មវត្ថុ** ៖ ករណីសំណើសុំពិនិត្យនិងសម្រេចលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ចំនួន០២គឺៈ

- សហគមន៍នេសាទត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត
- សហគមន៍នេសាទបឹងក្រពិត ឃុំមៀននិងឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ។

**យោង** ៖- អនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ

- ប្រកាសលេខ៣១៦ ប្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំពីសហគមន៍នេសាទ។

**ជូនភ្ជាប់**៖- លិខិតលេខ ០៩៨ ខរជ.តឃ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ របស់ខណ្ឌរដ្ឋបាលជលផលកំពត ស្តីពីសំណើសុំពិនិត្យនិងសម្រេចលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រពាំងសង្កែ

- លិខិតលេខ ០៩៨ ខរ.កព ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ របស់ខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ ស្តីពីសំណើសុំពិនិត្យនិងសម្រេចលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បឹងក្រពិត ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ យោង និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមប្រតិភូ** មេត្តាជ្រាបថា សហគមន៍នេសាទត្រពាំងសង្កែ ខេត្តកំពតនិងសហគមន៍នេសាទបឹងក្រពិត ខេត្តត្បូងឃ្មុំ មានការឧបត្ថម្ភគាំទ្រថវិកាពីអង្គការ FAO ហើយមានការសហការសម្របសម្រួលពីអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ខណ្ឌរដ្ឋបាលជលផលកំពតនិងត្បូងឃ្មុំ និងរដ្ឋបាលជលផលថ្នាក់កណ្តាល បានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទាំង២នេះ។ ផែនការគ្រប់គ្រងនេះនឹងជាមូលដ្ឋានគ្រឹះ ដែលជាយន្តការសម្រាប់ជំរុញដល់ដំណើរការគ្រប់គ្រងសហគមន៍នេសាទក្នុងការចូលរួមគ្រប់គ្រង ការពារ អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលរបស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព លើកកំពស់កម្រិតជីវភាពរស់នៅនិងកាត់បន្ថយភាពក្រីក្រ ស្របតាមគោលនយោបាយកំណែទម្រង់ស៊ីជម្រៅវិស័យជលផលរបស់រាជរដ្ឋាភិបាលកម្ពុជា។

អាស្រ័យហេតុនេះសូម **ឯកឧត្តមប្រតិភូ** មេត្តាពិនិត្យនិងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រតិភូ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ៕

រាជធានីភ្នំពេញ, ថ្ងៃទី 16 ខែ មិថុនា ឆ្នាំ២០១៧

**ប្រធានស្តីទីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ**

# សំណើសុំការសម្រេចនិងចុះហត្ថលេខាលើ
# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បឹងក្រពិត
# ក្នុងខេត្តត្បូងឃ្មុំ

សហគមន៍នេសាទបឹងក្រពិត នៅភូមិថ្មសំលៀង ឃុំមៀននិងឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ

ជូនភ្ជាប់ជាមួយនូវ

- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- បញ្ជីវត្តមានអ្នកចូលរួមប្រជុំពិភាក្សារៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ឯកសារពាក់ព័ន្ធផ្សេងៗ ។

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**
**ខេត្តត្បូងឃ្មុំ**
**ខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ**

លេខ.....០៩៨.....ខរជ.តឃ

ត្បូងឃ្មុំ, ថ្ងៃទី.....១៤.....ខែ.........ឆ្នាំ២០១៧

**នាយខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ**

**សូមគោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**តាមរយៈ** ៖ លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំ

**កម្មវត្ថុ** ៖ សំណើសុំពិនិត្យនិងសម្រេចលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បឹងក្រពិត ភូមិថ្មសំលៀង ឃុំ-មៀន និងឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ។

**យោង** ៖-អនុក្រឹត្យ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
-ប្រកាសនលេខ ៣១៦ ក្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមអនុញ្ញាតិជម្រាបជូន **ឯកឧត្តមប្រតិភូ**មេត្តាជ្រាបថា ចាប់តាំងពីរាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់វិស័យជលផល ខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ បានខិតខំជំរុញដំណើរការរៀបចំសហគមន៍នេសាទនៅទូទាំងខេត្ត បានយ៉ាងទូលំទូលាយ ដោយមានការចូលរួមយ៉ាងផុសផុលពីសំណាក់ប្រជាពលរដ្ឋ ហើយមានការគាំទ្រនិងសហការយ៉ាងល្អពីអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងមានការឧបត្ថម្ភពីអង្គការនានា។ ដំណើរការអនុវត្តន៍របស់សហគមន៍នេសាទបឹងក្រពិត បច្ចុប្បន្នមិនទាន់មានផែនការគ្រប់គ្រងនៅឡើយ ជាពិសេសផែនការគ្រប់គ្រងជាមូលដ្ឋានគ្រឹះនិងជាយន្តការសម្រាប់ជំរុញដំណើរការគ្រប់គ្រងសហគមន៍នេសាទក្នុងការចូលរួមគ្រប់គ្រង ការពារ អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលរបស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព លើកកំពស់កម្រិតជីវភាពរស់នៅនិងកាត់បន្ថយភាពក្រីក្រ ស្របតាមគោលនយោបាយកំណែទម្រង់ស៊ីជម្រៅវិស័យជលផលរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដូច្នេះខ្ញុំបាទសូមអនុញ្ញាតិ **ឯកឧត្តមប្រតិភូ** មេត្តាពិនិត្យនិងសម្រេចលើផែនការគ្រប់

គ្រងកន្លែងនេសាទសហគមន៍ ដើម្បីឱ្យមានការទទួលស្គាល់ជាផ្លូវការ។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើសូម **ឯកឧត្តមប្រតិភូ** មេត្តាពិនិត្យនិងសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រតិភូ** ទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ៕

**នាយខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ**

**អៀម ម៉ាយឌីរី**

លេខៈ ១១៩៧ កសក.ធយ

បានឃើញនិងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីពិនិត្យនិងសម្រេចដោយអនុគ្រោះ"

ត្បូងឃ្មុំ,ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០១៧

**ប្រធាន**

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំ**

**ហេង ពិសិដ្ឋ**